# ព្រះរាជសារ
# ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ
# នរោត្តម សីហមុនី
# ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

## ក្នុងឱកាសកិច្ចប្រជុំលើកទី១១
## នៃរដ្ឋភាគីអនុសញ្ញាអូតាវ៉ាស្តីពីការហាមប្រាមការប្រើប្រាស់មីនប្រឆាំងមនុស្ស

## ពីថ្ងៃទី ២៨ ខែវិច្ឆិកា ដល់ ថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១១

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមសំដែងនូវការអបអរសាទរនិងស្វាគមន៍យ៉ាងកក់ក្តៅ ជូនចំពោះគណៈប្រតិភូទាំងអស់ ដែលបានអញ្ជើញចូលរួម កិច្ចប្រជុំលើកទី១១ នៃរដ្ឋភាគីអនុសញ្ញាអូតាវ៉ាស្តីពីការហាមប្រាមការប្រើប្រាស់មីនប្រឆាំងមនុស្ស។ ប្រទេសនិងប្រជាជនកម្ពុជា មានកិត្តិយសនិងបុព្វសិទ្ធ ដែលបានស្វាគមន៍ពិភពលោកមកកាន់ទឹកដីកំណើតរបស់អនុសញ្ញា ក៏ដូចជាក្នុងការទទួលជាម្ចាស់ផ្ទះនិងជាប្រធាននៃកិច្ចប្រជុំ។ ក្នុងនាមជារដ្ឋភាគីដែលបានរងគ្រោះដោយសារមីន ខ្ញុំសូមជានាអះអាងនូវការប្តេជ្ញាចិត្តនិងការអនុវត្តជាក់ស្តែងរបស់យើងខ្ញុំក្នុងការលុបបំបាត់ នូវបញ្ហាមីនដែលមានជាយូរមកហើយនេះ និងសម្រេចឲបាននូវគោលដៅរួមរបស់យើងគឺពិភពលោកគ្មានគ្រាប់មីន។

ដោយបានទទួលស្គាល់នូវការបាត់បង់ផ្នែកមនុស្សធម៌ដោយសារមីន ក៏ដូចជាសុច្ឆន្ទៈរួមរបស់ពិភពលោកក្នុងការបន្តធ្វើឲការឆ្លើយតបទៅនឹងបញ្ហាប្រឈមផ្នែកមនុស្សធម៌នេះ កាន់តែប្រសើរថែមទៀត កម្ពុជាបានបណ្តាលឲមាននូវចលនាជាអន្តរជាតិ ដើម្បីហាមប្រាមនូវអាវុធទាំងនោះ ហើយនៅតែបន្តឈានមុខគេក្នុងការលើកស្ទួយការហាមប្រាមជាសកលផងដែរចាប់តាំងពីដើមរៀងមក។

មីននៅកម្ពុជា គឺជាកេរ្តិ៍ដំណែលដែលសង្គ្រាមប្រដាប់អាវុធ ៣០ ឆ្នាំ បានបន្សល់ទុក។ ការគាំទ្រផ្នែកហិរញ្ញវត្ថុពីបណ្តាដៃគូអភិវឌ្ឍន៍ពីឆ្នាំ ១៩៩២ ដល់ ខែសីហា ឆ្នាំ២០១១ បានជួយយើងដោះនិងកំទេចមីនជាង ៩ សែនគ្រាប់។ តែទោះជាយ៉ាងណា ផ្ទៃដីប្រមាណជា ៦៥០ គីឡូម៉ែត្រក្រឡាទៀត នៅមានការគំរាមដោយសារមីននៅឡើយ។ ត្បិតកម្ពុជា បានបោះជំហ៊ាននិងសម្រេចបាននូវសមិទ្ធផលដ៏ធំធេងក្នុងការដោះស្រាយបញ្ហាមីនចាប់តាំងពីបានក្លាយជារដ្ឋភាគីមក ប្រជារាស្ត្រជាទីស្រឡាញ់របស់ខ្ញុំមកពីសហគមន៍ដែលរងប៉ះពាល់ នៅតែបន្តរស់នៅដោយប្រឈមជាប្រចាំនូវការគំរាមកំហែងដល់ជីវិតនិងអាវៈយវៈខ្លួន ដោយសារអាវុធលាក់មុខនេះ ហើយកម្ពុជានៅតែជាប្រទេសមួយ ក្នុងចំណោមប្រទេសមានអត្រាគ្រោះថ្នាក់ដោយសារមីនខ្ពស់ជាងគេប្រចាំឆ្នាំក្នុងពិភពលោក។

ប្រទេសកម្ពុជា ទទួលស្គាល់ថា មីនមិនត្រឹមតែរាំងដល់ហេដ្ឋារចនាសម្ព័ន្ធសង្គមកិច្ច និងធ្វើឲប៉ះពាល់ដល់ការអភិវឌ្ឍនៅក្នុងបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួចប៉ុណ្ណោះទេ ប៉ុន្តែមីនថែមទាំងបានធ្វើឲស្ថានភាពនិង

ជីវភាពរស់នៅរបស់ប្រជាជនកាន់តែយ៉ាប់យ៉ឺនថែមទៀត ដែលពួកគាត់ត្រូវរងទុក្ខ ដោយសារមីនដែលសង្គ្រាមបានបន្សល់។ សម្រាប់កម្ពុជា ចក្ខុវិស័យរបស់យើងខ្ញុំគឺធ្វើឲកម្ពុជារួចចាកផុតពីការរងប៉ះពាល់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។ ខ្ញុំសូមថ្លែងអំណរគុណចំពោះប្រទេសជាមិត្ត និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានបន្តជួយយើងខ្ញុំដើម្បីសម្រេចឲបាននូវចក្ខុវិស័យនេះ។ ខ្ញុំក៏សូមសំដែងការដឹងគុណ ចំពោះអ្នកឯកទេសបរទេស ជនរួមជាតិ ជាពិសេសបងប្អូនជាអ្នកដោះមីន ដែលបានប្រថុយជីវិតបំពេញការងារ ក្នុងបុព្វហេតុដ៏ឧត្តុង្គឧត្តមនេះទាំងនៅកម្ពុជានិងនៅឯបរទេស។ តែទោះជាយ៉ាងណា យើងនៅតែត្រូវការនូវការប្តេជ្ញាចិត្ត និងការព្យាយាមបន្ថែមទៀត ដើម្បីសម្រេចឲបាននូវភារកិច្ចឲបានឆាប់បំផុតតាមដែលអាចធ្វើបាន សំដៅកាត់បន្ថយនូវការបាត់បង់អាយុជីវិត និងបង្កើននូវផលប្រយោជន៍សេដ្ឋកិច្ចសង្គមឲបានជាអតិបរមាសម្រាប់ប្រជាជនយើង។

ខ្ញុំជឿជាក់ថា កិច្ចប្រជុំលើកទី១១ នៃរដ្ឋភាគីអនុសញ្ញាអូតាវ៉ា នៅរាជធានីភ្នំពេញ នឹងផ្តល់នូវឱកាសមាសសម្រាប់អ្នកចូលរួមទាំងអស់បានរំលឹកឡើងវិញនូវការងារ ២០ ឆ្នាំកន្លងមករបស់យើង បានរាយការណ៍នូវវឌ្ឍនភាព និងសមិទ្ធផលសម្រេចបានក្នុងការធ្វើឲពិភពលោកយើងគ្មានគ្រាប់មីន ក៏ដូចជារំលេចនូវបញ្ហាប្រឈមដែលនៅមាន ជាពិសេសគឺការអះអាងសារជាថ្មីនូវការប្តេជ្ញាចិត្ត ក្នុងការធ្វើឲអនុសញ្ញាទទួលបានជោគជ័យសម្រាប់ពិភពលោកទាំងមូល និងសម្រាប់ប្រទេសយើងរៀងៗខ្លួនផងដែរ។

ជាទីបញ្ចប់ ខ្ញុំសូមអំពាវនាវដល់រដ្ឋភាគី រដ្ឋមិនមែនភាគី អង្គការអន្តរជាតិ និងសង្គមស៊ីវិលទាំងអស់ សូមបន្តនិរន្តរភាព និងលើកកម្ពស់ថែមទៀតនូវភាពជាដៃគូនិងកិច្ចសហប្រតិបត្តិការដែលមានកន្លងមក ដើម្បីរួមគ្នាបញ្ចប់នូវការរងទុក្ខដោយសារមីនឲបានឆាប់ និងរួមគ្នាលើកស្ទួយសិទ្ធិនិងសេរីភាពរបស់ជនរងគ្រោះ និងជនពិការ។ ខ្ញុំសូមប្រសិទ្ធពរជូន គណៈប្រតិភូទាំងអស់ដែលនឹងរួមគ្នាធ្វើសេចក្តីសម្រេចចិត្តដ៏មានសារសំខាន់ចំពោះភាពជោគជ័យនៃចលនាហាមប្រាមមីននេះ សូមអស់លោកបានប្រកបដោយជោគជ័យក្នុងកិច្ចខិតខំប្រឹងប្រែងនេះ។ សូមឲ កិច្ចប្រជុំលើកទី១១ នៃរដ្ឋភាគីអនុសញ្ញាអូតាវ៉ា ក្លាយជាវេទិកាដែលនឹងរុញច្រាន ឲបានសម្រេចនូវការលុបបំបាត់ទាំងស្រុងនូវបញ្ហាប្រឈមដោយសារមីន។